## ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
## អភិបូជាអគ្គសញ្ញាអាពាហ៍ពិពាហ៍
## ចំការទៀង ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩
## គម្រោងការដើម្បីបង្កើតគ្រួសារដ៏សុខសាន្ត

**អត្ថបទទី១៖ កំណើតពិភពលោក ១,២១-២៣**

ព្រះជាម្ចាស់ប្រទានពរដល់វា ដោយមានព្រះបន្ទូលថា៖ «ចូរបង្កើតកូនចៅឲ្យបានកើនចំនួនច្រើនឡើងពាសពេញក្នុងទឹកសមុទ្រ ហើយឲ្យបក្សាបក្សីបានកើនច្រើនឡើងលើផែនដីដែរ»។ កណ ១,២២

**ដំណឹងល្អ៖ យ៉ូហាន ១៥,១២-១៧**

គ្មាននរណាមានសេចក្ដីស្រឡាញ់ខ្លាំងជាងអ្នកដែលស៊ូប្ដូរជីវិត ដើម្បីមិត្តសម្លាញ់របស់ខ្លួននោះឡើយ។ យហ ១៥,១៣

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ យើងមានអំណរសប្បាយពិសេសសម្រាប់ព្រះសហគមន៍ ដោយសារជាថ្ងៃចន្ទបន្ទាប់ពីថ្ងៃបុណ្យព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ សម្រាប់យើងជាគ្រីស្តបរិស័ទជាថ្ងៃពិសេស។ ថ្ងៃនេះ យ៉ូហាន និងក្លរ៉ា ទទួលអគ្គសញ្ញាអាពាហ៍ពិពាហ៍ភ្ជាប់ជាមួយពន្លឺរបស់ព្រះគ្រីស្ត ដែលមានព្រះជន្មរស់ឡើងវិញម្សិលមិញ។ ខ្ញុំធ្លាប់និយាយជាមួយប្ដីប្រពន្ធដែលគេរៀបការហើយ និងជាមួយអ្នកដែលកំពុងមានសង្សារ **តើយើងនិយាយគ្នាអំពីអ្វីរាប់ម៉ោង? តើយើងបាននិយាយអំពីគម្រោងការសម្រាប់ថ្ងៃអនាគតរបស់យើងឬទេ? តើយើងរៀបចំគ្រួសារយ៉ាងដូចម្ដេច?** នេះជាអ្វីដែលសំខាន់គម្រោងការសម្រាប់អនាគត។ ថ្ងៃនេះ យើងទទួលអគ្គសញ្ញាអាពាហ៍ពិពាហ៍ជាមួយព្រះជាម្ចាស់ ត្រូវចូលនៅក្នុងគម្រោងការរបស់ព្រះជាម្ចាស់សម្រាប់យើង។ នៅក្នុងអត្ថបទដែលយើងធ្លាប់ស្ដាប់ "**ឲ្យយើងចេះស្រឡាញ់ភរិយានិងស្វាមីដូចព្រះយេស៊ូស្រឡាញ់ព្រះសហគមន៍ ឲ្យយើងចេះស្រឡាញ់គ្នាទៅវិញទៅមកដូចព្រះយេស៊ូបានស្រឡាញ់យើងដែរ**"។

យប់មិញ យើងបានឃើញគម្រោងការរបស់ព្រះជាម្ចាស់សម្រាប់មនុស្សលោក ព្រះជាម្ចាស់ស្ថិតស្ថេរជានិច្ចពីដើមរៀងមករហូតដល់ចុងក្រោយនៃពិភពលោក។ ព្រះជាម្ចាស់ បានបង្កើតបុរសនិងស្ត្រី ដើម្បីបន្តពូជឲ្យមានកូនច្រើន ដើម្បីបង្កើតគ្រួសារដ៏សុខសាន្ត។ ក្រោយមក គឺឲ្យយើងគ្រប់គ្រងផែនដីដែលយើងបានទទួល ដើម្បីឲ្យមនុស្សទាំងអស់មានម្ហូបអាហារគ្រប់គ្រាន់ ដើម្បីមនុស្សទាំងអស់មានសេចក្ដីសុខ។ គម្រោងការដ៏កំពូលរបស់ព្រះជាម្ចាស់ គឺណែនាំឲ្យមនុស្សយើងមានសុភមង្គល អត្ថបទទី២យប់មិញ ព្រះជាម្ចាស់បានឃើញប្រជារាស្ត្ររបស់ព្រះអង្គកំពុងរងទុក្ខលំបាក ធ្វើជាទាសករនៅក្នុងកណ្ដាប់ដៃជនជាតិអេហ្ស៊ីប ដូច្នេះព្រះអង្គបាន

ជ្រើសរើសលោកម៉ូសេ ដើម្បីរំដោះគេពីទុក្ខលំបាកឆ្ពោះទៅកាន់សេរីភាព។ ព្រះអង្គបានណែនាំឲ្យមនុស្សយើងមានសេចក្ដីសុខសុភមង្គល ដោយមានសេរីភាពប៉ុន្តែកុំប្រើសេរីភាពខុស ប្រសិនបើយើងប្រើសេរីភាពរបស់យើងខុស យើងបំផ្លាញទាំងអស់។ សេរីភាពរបស់យើងមានព្រំដែន យើងដឹងគ្រប់កាលៈទេសៈនៅក្នុងជីវិតយើងត្រូវការសិទ្ធិ ប៉ុន្តែព្រះជាម្ចាស់បានបង្កើតឲ្យយើងមានសេរីភាពដោយប្រើប្រាស់ឲ្យពោរពេញដោយសុភមង្គល។

ព្រះជាម្ចាស់បានចាត់ឲ្យព្រះយេស៊ូយាងមក ដើម្បីឲ្យមនុស្សយើងចូលនៅក្នុងសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់។ គម្រោងការរបស់ព្រះជាម្ចាស់ ណែនាំឲ្យយើងមានជីវិតអស់កល្បជានិច្ច ដោយសារព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។ ដោយសារ ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញថ្ងៃនេះ ពីរនាក់បានទទួលអគ្គសញ្ញាអាពាហ៍ពិពាហ៍ដោយមានសេចក្ដីស្រឡាញ់របស់ព្រះអង្គពោរពេញនៅក្នុងខ្លួន។ ដូច្នេះ ពេលគិតអំពីគម្រោងការអនាគតឲ្យយើងចូលនៅក្នុងគម្រោងការរបស់ព្រះជាម្ចាស់ បង្កើតបុរសនិងស្ត្រីឲ្យមានកូនច្រើន គ្រប់គ្រងផែនដីឲ្យស្អាតដើម្បីមនុស្សទាំងអស់មានសេចក្ដីសុខ ណែនាំឲ្យយើងមានសុភមង្គលនៅក្នុងសេរីភាព។ ប៉ុន្តែ ដោយប្រើប្រាស់សេរីភាពនៅក្នុងរបៀបត្រឹមត្រូវ និងចែករំលែកធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ដល់បងប្អូនឯទៀតៗ។ ប្រសិនបើ យើងចូលក្នុងគម្រោងការរបស់ព្រះជាម្ចាស់ដើម្បីបង្កើតគ្រួសារយើង យើងនឹងមានគ្រួសារដ៏សុខសាន្ត។

ជីវិតយើង យើងមិនអាចកាត់តដូចក្នុងកម្មវិធីកាត់តរូបថតឬវីដេអូទេ ប្រសិនបើជីវិតយើងកាត់តវានៅសល់ស្នាមរបួស។ ជីវិតរបស់យើងជាជីវិតពិត ដូច្នេះអ្វីៗទាំងអស់ដែលយើងធ្វើពីមួយថ្ងៃទៅមួយថ្ងៃ វាជាប់នៅក្នុងខ្លួនយើងអំពើល្អក្ដី អំពើអាក្រក់ក្ដី ភាពជោគជ័យក្ដី ភាពបរាជ័យក្ដី ហើយយើងខិតខំសាងសង់ជីវិតហ្នឹងរបៀបណាជាមួយព្រះជាម្ចាស់។ ជួនកាល យើងឈ្លោះគ្នាឲ្យយើងលើកលែងទោសឲ្យគ្នា យើងស្អប់គ្នាឲ្យយើងផ្សះផ្សាគ្នា យើងមានទុក្ខលំបាកនៅក្នុងជីវិតឲ្យយើងទៅមុខទៀត។ ជីវិតមានទុក្ខលំបាកច្រើនណាស់ យើងកាត់តមិនបានទេប៉ុន្តែយើងទៅមុខដោយសារយើងដឹងថាព្រះជាម្ចាស់ស្រឡាញ់យើង យើងមានគ្រួសារមួយយ៉ាងធំដែលយើងអាចទីពឹងបានជានិច្ច។

យើងអរព្រះគុណព្រះជាម្ចាស់ សូមព្រះអង្គប្រទានពរដើម្បីឲ្យប្ដីប្រពន្ធថ្មីនេះចូលនៅក្នុងគម្រោងការរបស់ព្រះជាម្ចាស់ ដើម្បីបង្កើតគ្រួសារដ៏សុខសាន្ត។ អាម៉ែន។